**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
**អគ្គនាយកដ្ឋានយោធសេវា**
**នាយកដ្ឋានព័ត៌មាន**
លេខ:..........................

# សេចក្តីប្រកាសព័ត៌មាន

តបតាមការអញ្ជើញរបស់សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា លោកជំទាវ ស្រីម៉ាទី នីម៉ាឡា ស៊ីថារ៉ាម៉ាន (Shrimati Nirmala Sitharman) រដ្ឋមន្ត្រីក្រសួងការពារប្រទេសនៃសាធារណរដ្ឋឥណ្ឌា នឹងដឹកនាំគណៈប្រតិភូអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី១០ រហូតដល់ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៨ ។

ក្នុងអំឡុងពេលទស្សនកិច្ច លោកជំទាវ ស្រីម៉ាទី នីម៉ាឡា ស៊ីថារ៉ាម៉ាន នឹងចូលជួបសវនកាជាមួយ សម្តេចពិជ័យសេនា ទៀ បាញ់ និងអញ្ជើញជាអធិបតីក្នុងពិធីចុះហត្ថលេខា កិច្ចសហប្រតិបត្តិការរវាងក្រសួងការពារជាតិនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការពារប្រទេសនៃសាធារណរដ្ឋឥណ្ឌា នៅអគារមិត្តភាពទីស្តីការគណៈរដ្ឋមន្ត្រី ។

លោកជំទាវ ស្រីម៉ាទី នីម៉ាឡា ស៊ីថារ៉ាម៉ាន នឹងដឹកនាំគណៈប្រតិភូចូលជួបសម្តែងការគួរសមចំពោះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានសន្តិភាព ទីស្តីការនាយករដ្ឋមន្ត្រីផងដែរ ។

ថ្ងៃសុក្រ ១០រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៨